វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

ឯកសារស្រាវជ្រាវសង្ខេប
គណៈកម្មការទី៦ នៃព្រឹទ្ធសភា

# តួនាទី និងភារកិច្ចរបស់មេធាវី នៅប្រទេសកម្ពុជា

ខែកុម្ភៈ ឆ្នាំ២០១៧


អ្នកស្រាវជ្រាវ៖ កញ្ញា ហេង នីដា
ចូលរួមដោយ៖ កញ្ញា ជា សុគន្ធមិនា
លោកស្រី វ៉ាន់ ណារី

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈ ការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌលឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភាឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

## មាតិការ


១. សេចក្តីផ្តើម ........................................................................................................................ 1

២. សារៈសំខាន់របស់មេធាវីនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ............................................................. 1

៣. តួនាទី និងភារកិច្ចរបស់មេធាវីនៅកម្ពុជា........................................................................................2

 ៣.១. តួនាទីរបស់មេធាវីនៅកម្ពុជា...............................................................................................3

 ៣.២. ភារកិច្ចរបស់មេធាវីនៅកម្ពុជា ............................................................................................3

៤. បញ្ហាប្រឈម ...........................................................................................................................5

៥. សេចក្តីសន្និដ្ឋាន ......................................................................................................................6

## ១. សេចក្តីផ្តើម

ដោយមើលឃើញពី សារៈសំខាន់នៃវិជ្ជាជីវៈផ្នែកច្បាប់ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ ១៩៩៥[1] បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើម ឲ្យមានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងឆ្នាំ១៩៩៣។[2] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានផ្តល់ឲ្យវិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ ដើម្បីផ្តល់សេវា យុត្តិធម៌។ ប៉ុន្តែវិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបាន តែក្នុងក្របខ័ណ្ឌនៃគណៈមេធាវីតែប៉ុណ្ណោះ។[3]

ឯកសារស្រាវជ្រាវសង្ខេបនេះ នឹងផ្តល់នូវការសិក្សាអំពី តួនាទី និងភារកិច្ចរបស់មេធាវីនៅកម្ពុជា ក៏ដូចជា បញ្ហាប្រឈមរបស់មេធាវី ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ គន្លឹះសំខាន់ៗ នៃការរកឃើញតាមរយៈការ ស្រាវជ្រាវ ដើម្បីដោះស្រាយសំណួរ ស្រាវជ្រាវសំខាន់បួនរួមមាន៖

១. តើមេធាវីមានសារៈសំខាន់យ៉ាងដូចម្តេចក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា?
២. តើអ្វីទៅជាតួនាទី និងភារកិច្ចរបស់មេធាវីនៅកម្ពុជា?
៣.តើអ្វីទៅជាបញ្ហាប្រឈមក្នុងការបំពេញភារកិច្ចរបស់មេធាវី ដើម្បីការពារកូនក្តីរបស់ខ្លួន?
៤.តើគួរមានយន្តការ និងនីតិវិធីដូចម្តេចខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយរបស់ មេធាវី ក្នុងការបំពេញកិច្ចការពារកូនក្តីរបស់ខ្លួន?

## ២. សារៈសំខាន់របស់មេធាវីនៅក្នុងប្រព័ន្ធតុលាការកម្ពុជា

មេធាវីមានបេសសកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស យោង តាមមាត្រា៤ នៃច្បាប់ស្តីពី ក្រមសីលធម៌មេធាវី។[4] គណៈមេធាវីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការ (១)ធ្វើឲ្យមានគុណភាពវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ (២)ការពារសមាជិករបស់ខ្លួនពីការគំរាម កំហែង និង ការជ្រៀតជ្រែកមិនត្រឹមត្រូវណាមួយ និង(៣) ណែនាំមេធាវី ដើម្បីធានាឲ្យមេធាវីផ្តល់សេវា ច្បាប់ដល់កូនក្តីទាំងអស់។[5] បើយោងតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពី តួនាទីរបស់មេធាវី (UN Basic Principles on the Role of Lawyers) គណៈមេធាវីគួរតែ សហការ ជាមួយរាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នផ្សេងៗ ដើម្បីការពារផលប្រយោជន៍សាធារណៈ និងលើកកម្ពស់ យុត្តិធម៌ ដោយធានាថាមនុស្សគ្រប់រូបទទួលបានការផ្តល់សេវាច្បាប់ ប្រកបដោយប្រសិទ្ធភាព និងស្មើ ភាពគ្នា។[6]

ឧទាហរណ៍ មាត្រា ៣០០ នៃច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ជនជាប់ចោទត្រូវអមដោយ មេធាវីម្នាក់ ដែលខ្លួនបានជ្រើសរើស ហើយជនជាប់ចោទក៏អាចស្នើសុំឲ្យចាត់តាំង មេធាវីសម្រាប់ខ្លួនបាន

ដែរ ដោយផ្អែកក្នុងច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី។[7] បន្ថែមពីនេះទៀត អនីតិជន និងជនជាប់ចោទ ពីបទឧក្រិដ្ឋ មិនអាចចូលខ្លួនក្នុងតុលាការ ដោយគ្មានវត្តមានមេធាវីបានទេ។[8] ក្នុងករណីដែល ជនជាប់ចោទមិនមានលទ្ធភាពចំណាយលើថ្លៃមេធាវីបាន រាជរដ្ឋាភិបាល ឬគណៈមេធាវីត្រូវតែផ្តល់មេធាវីដល់ពួកគេ ។[9] គណៈមេធាវី គឺជាស្ថាប័នដែលតំណាងឲ្យមេធាវី ជាអង្គការមិនមែនរដ្ឋាភិបាល និងមានឯករាជ្យវិជ្ជាជីវៈក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងច្បាប់ស្តីពី លក្ខន្តិកៈមេធាវី។[10]

យោងតាមមាត្រា២៩ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី មូលនិធិគណៈមេធាវី ត្រូវបានបង្កើតឡើយដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (គណៈមេធាវី) ដែលមានឈ្មោះថា "វិភាគទានគណៈមេធាវី"។[11] ការអនុវត្តជាក់ស្តែង ជំនួយផ្នែកច្បាប់នៅកម្ពុជាត្រូវបានបែងចែកជា ៣ផ្នែក គឺ(១) រាល់សមាជិកគណៈមេធាវីត្រូវបង់វិភាគទានជារៀងរាល់ឆ្នាំទៅឲ្យមូលនិធិគណៈមេធាវី។[i12] (២)រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាជំនួយផ្នែកច្បាប់ជារៀងរាល់ឆ្នាំ (៣) ជំនួយផ្នែកច្បាប់ផ្សេងទៀត ក៏ត្រូវបាន ផ្តល់ដោយវិស័យឯកជនអង្គការ ឬរដ្ឋាភិបាលបរទេស។[13]

មូលនិធិរបស់គណៈមេធាវី ត្រូវបានប្រើប្រាស់សម្រាប់សកម្មភាព និងតម្រូវការរបស់គណៈមេធាវី ដូចជាសម្រាប់ "ឧបត្ថម្ភទៅឱ្យមេធាវីដែលបានការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ"។[14]

មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានផ្តល់មេធាវី ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ឬផ្តល់ជំនួយផ្នែកច្បាប់ ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។[15] ដូចគ្នានេះដែរ ជំនួយផ្នែកច្បាប់នេះ អាចការពារ ពីការធ្វើទណ្ឌកម្មក្នុងអំឡុងពេលឃុំខ្លួន និងកាត់បន្ថយការផ្តន្ទាទោសខុសច្បាប់។[16]

## ៣. តួនាទី និងភារកិច្ចរបស់មេធាវីនៅកម្ពុជា

យោងតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពី តួនាទីរបស់មេធាវីនៅកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការធានានីតិរដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ មេធាវី មិនត្រូវស្ថិតនៅក្រោមការរឹតត្បិត ឬជ្រៀតជ្រែកណាមួយឡើយ។[17]

ក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីនៅកម្ពុជាដើរតួជាអ្នកបកស្រាយច្បាប់ ក៏ដូចជាពន្យល់ពីអត្ថន័យ និងសារៈសំខាន់នៃច្បាប់ទាំងនោះទៅកាន់ប្រជាពលរដ្ឋ។[18] លើសពីនេះទៀត ក្នុងករណីដែលច្បាប់ណាមួយ មិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋ មេធាវីក៏អាចផ្តល់ជាជំនួយក្នុងការប្រឹក្សា ដើម្បីធ្វើការ

[i] យោងតាមវិធានផ្ទៃក្នុងរបសគណៈមេធាវី មាត្រា៥បានចែងថា "មេធាវីជាតិ និងមេធាវីបរទេសត្រូវតែបង់វិភាគទានទៅគណៈមេធាវី ដោយយោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី"

កែសម្រួលច្បាប់នោះផងដែរ។ នៅក្នុងដំណើរការច្បាប់ មេធាវីអាចផ្តល់ជាជំនួយដល់សមាជិកសភា នូវបទពិសោធន៍ និងការប្រឹក្សាយោបល់ ទាក់ទងទៅនឹងការអនុវត្តច្បាប់ ខណៈពេលដែលមេធាវីមាន តួនាទីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងដាក់ពាក្យបណ្តឹង ប្រសិនបើអាជ្ញាធរណាមួយរំលោភលើច្បាប់។ ក្រៅពីនេះមេធាវី ដើរតួនាទីជាតំណាងកូនក្តីរបស់ខ្លួន នៅក្នុងដំណើរការតុលាការ និងតវ៉ាក្តី ដើម្បីការពារសិទ្ធិរបស់កូនក្តីចំពោះមុខតុលាការ។[19] មេធាវីទាំងអស់មាន ភារកិច្ចរក្សា ការសម្ងាត់របស់កូនក្តី។[20]

### ៣.១. តួនាទីរបស់មេធាវីនៅកម្ពុជា

ខណៈពេលដែលមេធាវីដើរតួនាទីយ៉ាងសំខាន់ក្នុងរឿងពាណិជ្ជកម្ម ការងារ និងរឿងក្តីរដ្ឋបាល ផ្នែកនេះនឹងផ្តោតសំខាន់លើ ករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីតែប៉ុណ្ណោះ។[21]

- **រឿងក្តីព្រហ្មទណ្ឌ៖** ព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្តឹងអាជ្ញា ដើម្បីការពារផលប្រយោជន៍សាធារណៈ ចំនែកឯមេធាវី មានតួនាទីការពារជនត្រូវចោទ ឬជនជាប់ចោទ។ លើសពីនេះទៀត មេធាវីអាចធ្វើជាតំណាងឲ្យជនរងគ្រោះបានក្នុងករណីបណ្តឹងរដ្ឋប្បវេណី យោងតាមមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ មេធាវី អាចសាកសួរទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបអង្កេត ឬកោសល្យវិច្ច័យ លើភស្តុតាងដែលបានរកឃើញ។ ភស្តុតាងទាំងអស់ដែលមេធាវី បានរកឃើញ ត្រូវបង្ហាញនៅចំពោះមុខចៅក្រម ដើម្បីពិនិត្យ និងពិចារណា។[22]
- **រឿងក្តីរដ្ឋប្បវេណី៖** ក្នុងរឿងក្តីរដ្ឋប្បវេណី មេធាវីអាចការពារកូនក្តីក្នុងដំណើរការតុលាការ។ ប៉ុន្តែត្រូវមានកិច្ចព្រមព្រៀងការពារក្តី រវាងមេធាវី និងកូនក្តីជាមុនសិន នេះបើយោងតាមមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[23]

### ៣.២. ភារកិច្ចរបស់មេធាវីនៅកម្ពុជា

យោងតាមច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី និងវិធានផ្ទៃក្នុងរបស់គណៈមេធាវី តួនាទី និងភារកិច្ចរបស់មេធាវីនៅកម្ពុជាត្រូវបានបែងចែកជាបីប្រភេទសំខាន់ៗ ដូចជា ភារកិច្ចជាសមាជិកនៃសមាគមន៍វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈបម្រើឲ្យកូនក្តី និងជាវិជ្ជាជីវៈផ្នែកច្បាប់ដែលបម្រើក្នុងប្រព័ន្ធយុត្តិធម៌។[24]

- ***ភារកិច្ចក្នុងវិជ្ជាជីវៈ៖*** មេធាវីមានកាតព្វកិច្ច ការពារ រក្សាកិត្យានុភាពរបស់ខ្លួន និងគិតពីផលប្រយោជន៍សាធារណៈ ជាជាងខ្លួនឯង។ ក្រៅពីនេះ មេធាវីនឹងធ្វើឱ្យប្រាកដថាសេវាផ្នែកច្បាប់នេះ នឹងផ្តល់ជូនដល់ប្រជាពលរដ្ឋគ្រប់រូប មិនថាអ្នកមាន និងអ្នកក្រីក្រ។ ដូច្នេះ មេធាវីត្រូវចូលរួមក្នុងកម្មវិធីជំនួយផ្នែកច្បាប់ ដូចដែលមានចែងក្នុងមាត្រា៥២ នៃក្រមសីលធម៌មេធាវី "មេធាវី ត្រូវទទួលរ៉ាប់រង ដោយរៀសវ៉ៃ និងហ្មត់ចត់នូវបេសសកម្ម និង

សេវារួម ព្រមទាំងការការពារក្តីជូនជនក្រីក្រ ដែលបានប្រគល់ឲ្យដោយគណៈមេធាវី និងមិនយកកម្រៃ។ មេធាវីមិនអាច ប្រកែកមិនទទួល ការងារទាំងឡាយណាដែល គណៈមេធាវីបានប្រគល់ឲ្យ ដោយគ្មានមូលហេតុសមស្របឡើយ”។[25] លើសពីនេះទៀត មេធាវីត្រូវតែជាសមាជិករបស់គណៈមេធាវី យោងតាមមាត្រា៤ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ។[26]

- **ភារកិច្ចចំពោះកូនក្តី៖** មេធាវី ជាតំណាងឲ្យកូនក្តី។ មេធាវីប្រើចំណេះដឹង និងជំនាញ ដើម្បីការពារកូនក្តី នៅចំពោះមុខតុលាការ។ តាមរយៈការផ្តល់សេវាច្បាប់ និងកសាងជំនឿទុកចិត្តដល់កូនក្តី មេធាវីត្រូវ (ក)ពិភាក្សាជាមួយកូនក្តីពាក់ព័ន្ធនឹងរឿងក្តី (ខ)ស្វែងរកអង្គហេតុ និងអង្គច្បាប់ ដែលពាក់ព័ន្ធ (គ)ផ្តល់នូវដំបូន្មាន ដល់កូនក្តីអំពីសិទ្ធិរបស់ពួកគេ និង(ឃ) រៀបចំឯកសារ និងការពារកូនក្តី ក្នុងពេលជម្រះក្តី។[27]

**ក. ការដាក់ពាក្យបណ្តឹង៖** មេធាវីនឹងសួរកូនក្តី ដើម្បីកំណត់ពីកម្មវត្ថុ នៃការដាក់ពាក្យបណ្តឹង មេធាវីអាចជាតំណាងឱ្យកូនក្តីតាមរយៈកិច្ចព្រមព្រៀង ឬការពារក្តី និងនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ មុនពេលដែលពួកគេបានដាក់ពាក្យបណ្តឹង។ ក្នុងករណីរដ្ឋប្បវេណី ប្រសិនបើពាក្យបណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយមានចំនុចខ្វះខាតដែល មិនអាចកែតម្រូវបាន តុលាការអាចលើបណ្តឹងនោះចោល។[28] មេធាវីអាចពន្យល់ដល់កូនក្តីទាក់ទង នឹងនីតិវិធីតុលាការ និងគុណវិបត្តិរបស់រឿងក្តីនោះ។ លើសពីនេះទៀត មេធាវីនឹងកំណត់ពីអង្គហេតុ និងអង្គច្បាប់ នៅក្នុងគោលបំណង ដើម្បីសរសេរពាក្យបណ្តឹងទៅតុលាការ។[29]

**ខ. មុនពេលជំនុំជម្រះ៖** ក្នុងករណីព្រហ្មទណ្ឌ នៅពេលដែលជនត្រូវចោទបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះពីបទចោទប្រកាន់ និងអំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ជនត្រូវចោទមានសិទ្ធិឆ្លើយ និងមិនឆ្លើយ។ ចៅក្រមស៊ើបសួរ នឹងប្រាប់ជនត្រូវចោទពីសិទ្ធិក្នុងការជ្រើសរើសមេធាវីម្នាក់ ឬអាចស្នើសុំឲ្យចាត់តាំងមេធាវីសម្រាប់ខ្លួនបានផងដែរ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[30]

នៅពេលជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចប្រាំថ្ងៃ មុនការសួរចម្លើយ។ ក្នុងអំឡុងពេលនោះ មេធាវីអាចពិនិត្យមើលសំណុំរឿងមុនបាន។[31]

បន្ទាប់ពី សួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរអាចសម្រេចថាឃុំ ឬមិនឃុំខ្លួន តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមរយៈសំណើរបស់ព្រះរាជអាជ្ញា។ នៅក្នុងករណីនេះ មេធាវីត្រូវបង្ហាញពីមធ្យោបាយ ការពារកូនក្តីរបស់ខ្លួន។[32] មេធាវី ឬជនត្រូវចោទ អាចដាក់ពាក្យស្នើសុំទៅចៅក្រម

ស៊ើបសួរ ដើម្បីឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។[33] មេធាវី ត្រូវតែផ្តល់នូវហេតុផលច្បាស់លាស់ ដើម្បីធានាកូនក្តីខ្លួនឲ្យនៅក្រៅឃុំ។

**គ. អំឡុងពេលជំនុំជម្រះ៖** មេធាវីមានតួនាទីយ៉ាងសំខាន់នៅក្នុងនីតិវិធីសវនាការ ដើម្បីចង្អុលបង្ហាញពីអង្គហេតុ និងអង្គច្បាប់ ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជូនកូនក្តី។

- **ការបង្ហាញអង្គហេតុ៖** មេធាវីត្រូវដោះស្រាយជម្លោះ តាមរយៈសេចក្តីថ្លែងការណ៍ដែលមានផលប្រយោជន៍ដល់កូនក្តី។ លើសពីនេះទៅទៀត មេធាវីនឹងបង្ហាញពីភស្តុតាងដោះបន្ទុកទៅតុលាការ ដូចជា សាក្សី និងភស្តុតាង ដែលជាប្រយោជន៍ផ្សេងទៀតចំពោះកូនក្តីរបស់ខ្លួន។
- **ការបង្ហាញអង្គច្បាប់៖** មេធាវីត្រូវផ្ទៀងផ្ទាត់សំណួរនៃអង្គច្បាប់ ថាតើច្បាប់ណាដែលនឹងត្រូវយកមកប្រើ ដើម្បីដោះស្រាយជាមួយនឹងអង្គហេតុ។ មេធាវីនឹងធ្វើការពាររឿងក្តី តាមរយៈការលើកឡើងនូវមាត្រានៃច្បាប់ ដើម្បីឆ្លើយតបនឹងអង្គហេតុក្នុងអំឡុងពេលដំណើរការជំនុំជម្រះក្តី។
- **សេចក្តីសន្និដ្ឋានការពារ៖** មុនពេលចៅក្រមសម្រេចសេចក្តី មេធាវីនឹងធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តី ដែលមេធាវីនឹងស្នើទៅតុលាការ ដូចជាសុំឲ្យមានសំណងជំងឺចិត្ត និងអាចធ្វើការបដិសេធពាក្យចោទ របស់ភាគីម្ខាងទៀត។
- **ភារកិច្ចចំពោះតុលាការ៖** មេធាវី មានកាតព្វកិច្ច ដើម្បីជួយដល់តុលាការ ឱ្យសម្រេចបាននូវយុត្តិធម៌។ ដូច្នេះ មេធាវីទាំងអស់ មិនត្រូវបង្ហាញភស្តុតាងមិនពិតណាមួយ នៅចំពោះមុខតុលាការនោះទេ។ ទោះយ៉ាងណា បើកូនក្តីមិនចង់ឱ្យមេធាវីបង្ហាញ អង្គហេតុជាក់លាក់ណាមួយ ដែលទាក់ទងនឹងកូនក្តីប្រព្រឹត្តខុស មេធាវីត្រូវតែគោរពតាមការសម្រេចចិត្តរបស់កូនក្តី ព្រោះនេះមិន មែនជាភារកិច្ចរបស់មេធាវី ក្នុងការចាប់កំហុសកូនក្តីនោះទេ។[34]

## ៤. បញ្ហាប្រឈម

កង្វះខាតជំនួយផ្នែកច្បាប់ ជាផ្នែកមួយនៃឧបសគ្គចម្បង ដើម្បីទទួលបានសេវាយុត្តិធម៌នៅកម្ពុជា។ យោងតាមអ្នកជំនាញ រាជរដ្ឋាភិបាលបានផ្តល់នូវថវិកាជំនួយផ្នែកច្បាប់ ជាពិសេសសម្រាប់ករណីព្រហ្មទណ្ឌ ដែលមានថវិកាប្រមាណជា ៣០០លានរៀល (ឬ ៧៥.០០០ ដុល្លារអាមេរិក) ក្នុងមួយឆ្នាំ ដើម្បីឧបត្ថម្ភ លើការចំណាយ ដើម្បីឲ្យពលរដ្ឋទទួលបានសេវាយុត្តិធម៌នៅគ្រប់ខេត្តក្រុង។[35]

បើប្រៀបធៀបទៅនឹងថវិកា ជំនួយផ្នែកច្បាប់របស់រាជរដ្ឋាភិបាលថៃក្នុងឆ្នាំ២០១៤ មានចំនួន ៤៥៩,៤៧២,២៤៣.២៧ ដុល្លារអាមេរិក (១៤,៥៩០.៨ លានបាត) ដើម្បីធានាថាប្រជាពលរដ្ឋទទួលបាននូវសេវាយុត្តិធម៌ និងពង្រឹងសេវាជំនួយផ្នែកច្បាប់ឲ្យកាន់តែរឹងមាំថែមទៀត។[36] ជំនួយផ្នែកច្បាប់នៅកម្ពុជាគឺនៅមានចំនួនតិចតួច ដែលមិនគ្រប់គ្រាន់ សូម្បីតែចំណាយលើថ្លៃសេវាមេធាវី។ នេះអាចជា កត្តាមួយដែលពិបាកក្នុងការជ្រើសរើសមេធាវី ទៅធ្វើការនៅតាមបណ្ដាខេត្តនានា។[37]

ទិន្នន័យជាក់លាក់ពីជំនួយផ្នែកច្បាប់នៅកម្ពុជានៅមានកម្រិតនៅឡើយ។ ទោះជាយ៉ាងណា កង្វះខាតនៃការផ្ដល់ថវិកាខាងលើនេះ អាចបណ្ដាលឱ្យសេវាផ្នែកច្បាប់នៅមានកម្រិត ដោយសារតែ មេធាវីមិនមានពេលវេលាគ្រប់គ្រាន់ ក្នុងការស៊ើបអង្កេត និងជួបជាមួយកូនក្ដីរបស់ពួកគេ។[38] លើសពីនេះទៀត បើយោងតាមអ្នកជំនាញ[39] មិនមានគោលនយោបាយ ជំនួយផ្នែកច្បាប់ជាក់លាក់ណាមួយ ដើម្បីដោះស្រាយបញ្ហាទាំងនេះទេ។ ដើម្បីដោះស្រាយបញ្ហាទាំងនោះ រាជរដ្ឋាភិបាលអាចពិចារណា ទៅលើជម្រើស គោលនយោបាយមួយចំនួន ដូចជាការបង្កើនថវិកាជំនួយផ្នែកច្បាប់ និងបង្កើតយុទ្ធសាស្ត្របន្ថែមទៀត ដើម្បីធានាឱ្យបាននូវកម្មវិធីជំនួយផ្នែកច្បាប់ដ៏រឹងមាំ ដែលអាចផ្ដល់សេវាយ៉ាងមានប្រសិទ្ធិភាព ដល់អ្នកដែលត្រូវការជំនួយផ្នែកច្បាប់។

នៅក្នុងប្រទេសកម្ពុជា គឺមានសមាគមគណៈមេធាវីតែមួយគត់ នៅរាជធានីភ្នំពេញ។ ដូច្នេះ មេធាវីទាំងអស់ធ្វើការនៅក្នុងទីក្រុង ជាជាងនៅតាមបណ្ដាខេត្ត។ ផ្ទុយពីប្រទេសបារាំង សមាគមគណៈមេធាវី ដែលផ្ដល់ជំនួយផ្នែកច្បាប់ មានមូលដ្ឋាននៅគ្រប់បណ្ដាលខេត្ត/ក្រុងទូទាំងប្រទេស។[40] កង្វះខាតនៃសមាគមគណៈមេធាវី គឺជាបញ្ហាចម្បងក្នុងការបង្កើន និងនាំយកនូវសេវាច្បាប់ ឲ្យខិតជិតប្រជាពលរដ្ឋមូលដ្ឋាន។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលអាចពិចារណាជម្រុញឲ្យមានការបង្កើត សមាគមន៍គណៈមេធាវីបន្ថែមទៀត ជាពិសេសនៅតាមបណ្ដាលខេត្តក្រុងនានា ដើម្បីធានាថានឹងមានមេធាវីគ្រប់គ្រាន់ដើម្បី គាំទ្រដល់សេវាជំនួយផ្នែកច្បាប់។

## ៥. សេចក្ដីសន្និដ្ឋាន

មេធាវីមានកាតព្វកិច្ច ផ្ដល់សេវាច្បាប់ និងជាតំណាងស្របច្បាប់ ក្នុងការការពារផលប្រយោជន៍ របស់កូនក្ដី។ ទោះជាយ៉ាងណា បញ្ហាប្រឈមនៅតែមានចំពោះមេធាវី ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឲ្យបានពេញលេញ ដូចជា ជំនួយផ្នែកច្បាប់នៅមានកម្រិត កង្វះខាតមេធាវី កង្វះខាតសមាគមន៍គណៈមេធាវី នៅតាមបណ្ដាលខេត្តក្រុង ដែលធ្វើឲ្យការទទួលសេវាយុត្តិធម៌ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន មានភាពងាយស្រួល។ រាជរដ្ឋាភិបាល អាចដោះស្រាយបញ្ហាទាំងអស់នោះបាន តាមរយៈការផ្ដល់ថវិកា ជំនួយ

ផ្នែកច្បាប់បន្ថែមទៀត និងជម្រុញឲ្យមានការបង្កើតសមាគមន៍គណៈ មេធាវីនៅតាមបណ្ដាលខេត្តក្រុង ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ លើសិទ្ធិក្នុងតុលាការ និងការទទួលបានសេវាវិជ្ជាជីវៈច្បាប់បានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធិភាព។

[1] National Assembly, (1995). *Law on the Bar.* Phnom Penh: National Assembly, p 16. Available at: https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_50.pdf [Accessed 01 Feb. 2017]
[2] Royal Government of Cambodia (RGC), (2014). *National Strategic Development Plan 2014-2018.* Phnom Penh: RGC, p1
[3] Law on the Bar, Article 1.
[4] Dorine. V. van der Keur, (2014). *Raising the Cambodian Bar.*
[5] UN, (1990). *Basic Principle on the Role of Lawyers.* Cuba: Havana. Available at: https://www.un.org/ruleoflaw/blog/document/basic-principles-on-the-role-of-lawyers/ [accessed on 03 Feb. 2017]
[6] Ibid.
[7] Ministry of Justice, (2007). *Cambodian Code of Criminal Procedure.* Phnom Penh : MoJ. Article 300.
[8] *Cambodian Code of Criminal Procedure.* Article 303.
[9] National Assembly, (1995). *Law on the Bar.* Article 29.
[10] The Khmer Institute of Democracy. *Role of the* Lawyer. p. 33. Available at: http://www.khmerrough.com/pdf/CriticalThinking-Eng/Part4-CriticalThinking.pdf . [Accessed on 03 Feb 2017].
[11] BACK,. *Bank Account of BACK Contribution.* [online] Available at: http://www.bakc.org.kh/en/ [accessed on 03 Feb. 2017]
[12] National Assembly, (1995). *Law on the Bar.* Article 29.
[13] Ibid.
[14] Ibid.
[15] Ibid.
[16] Ibid.
[17] UN, (1990). *Basic Principle on the Role of Lawyers.*
[18] Law on the Bar, Article 3
[19] Ibid.
[20] Law on the Bar, Article 19
[21] Law on the Bar, Article 3
[22] Hun, B. *Mission, Roles, and Duties of Lawyers*.
[23] Law on the Bar, Article 2
[24] Hun, B. *Mission, Roles, and Duties of Lawyers*.
[25] Ibid. pp. 35-36.
[26] *The Law on the Bar.*
[27] The Khmer Institute of Democracy. *Role of the* Lawyer. p. 37.
[28] Ministry of Justice, (2007). *Civil Code Procedure.* Article 81
[29] Ibid. Article 75
[30] Ministry of Justice, (2007). *Criminal Code Procedure.* Article 143
[31] Ibid. Article 145
[32] Ibid. Article 206
[33] Ibid. Article 217 and 245
[34] Ibid. p. 38.
[35] Run, S. (2016). *Role of Professional Bodies and Legal Aid Organizations in Cambodia.* Bangkok. Available at http://www.lrct.go.th/en/wp-content/uploads/2016/04/S3-3-Run-Saray-Legal-Aid-Cambodia.pdf [ 08 Feb 2017]
[36] Office of Law Reform Commission of Thailand, (2014). *Thailand National Report on Legal Aids.* Taipei : Taiwan. Available at http://www.laf.org.tw/ifla2014/en/download/Report_Thailand.pdf [access on 20 Feb 2017]
[37] Run, S. (2016). *Role of Professional Bodies and Legal Aid Organizations in Cambodia.*
[38] Ibid.
[39] Ibid.
[40] Prisoners Abroad, (2005). *Factsheet France Legal System (Remand).* London: United Kingdom. Available at http://www.legalaidreform.org/national-legal-aid-systems/national-legal-aid-systems-by-country/item/739-france [access on 20 Feb 2017].